# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យនស/រកត/០១០០/០០៨

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ទតសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងអនុសញ្ញាដទៃទៀតដែលកម្ពុជាបានចូលជាភាគី
- បានទ្រង់ទតសំណើរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០០

ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានបង្កើតគណៈកម្មាធិការមួយរបស់រាជរដ្ឋាភិបាលមានឈ្មោះថា " គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា " ដើម្បីការពារ អភិវឌ្ឍន៍ និងលើកកំពស់សិទ្ធិមនុស្សនៅកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានអក្សរកាត់ថា " គសមក " ។

មាត្រា ២ .- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា រួមមានសមាសភាព ៖

| | | |
|---|---|---|
| ១-ឯកឧត្តម អុំ យ៉ិនទៀង | ជាប្រធាន មានឋានៈស្មើ | រដ្ឋមន្ត្រី |
| ២-ឯកឧត្តម អ៊ុក វណ្ណរិទ្ធ | ជាអនុប្រធាន មានឋានៈស្មើ | រដ្ឋលេខាធិការ |
| ៣-ឯកឧត្តម ចាន់ មិន | ជាអនុប្រធាន មានឋានៈស្មើ | រដ្ឋលេខាធិការ |
| ៤-ឯកឧត្តម យឹម គុនវិចាន | ជាសមាជិក មានឋានៈស្មើ | អនុរដ្ឋលេខាធិការ |
| ៥-ឯកឧត្តម ឆេង ស៊ីផន | ជាសមាជិក មានឋានៈស្មើ | អនុរដ្ឋលេខាធិការ |

Downloaded from http://www.khmerlaws.com

៦-ឯកឧត្តម ម៉ុន ពិសិទ្ធ ជាសមាជិក មានឋានៈស្មើអនុរដ្ឋលេខាធិការ

៧-ឯកឧត្តម ហែម ក្រាញ់ ត្នាន់ ជាសមាជិក មានឋានៈស្មើអនុរដ្ឋលេខាធិការ

៨-ឯកឧត្តម ហោ ឡុត ជាសមាជិក និងជាតំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈមានឋានៈស្មើអនុរដ្ឋលេខាធិការ

៩-ឯកឧត្តម អ៊ិន ពីទ្ធី ជាសមាជិក និងតំណាងក្រសួងយុត្តិធម៌ មានឋានៈស្មើអនុរដ្ឋលេខាធិការ

១០-លោកជំទាវ តាន់ ធានី ជាសមាជិក និងជាតំណាងគណៈកម្មាធិការឡូតូមានឋានៈស្មើអនុរដ្ឋលេខាធិការ

១១-លោកជំទាវ ទុំ ចាន់ធីនី ជាសមាជិក មានឋានៈស្មើអនុរដ្ឋលេខាធិការ

១២-លោកជំទាវ គុណ ធីតា ជាសមាជិក មានឋានៈស្មើអនុរដ្ឋលេខាធិការ

**មាត្រា ៣**.- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាជួយដល់រាជរដ្ឋាភិបាលក្នុងការងារ ៖

-ការពារលើកស្ទួយ អភិវឌ្ឍន៍សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និងពាក្យបណ្តឹងនានា ។

-ស្រាវជ្រាវអង្កេតករណីនានា ឬ ធ្វើការវាយតម្លៃការស្រាវជ្រាវអង្កេតរបស់សមត្ថកិច្ច ឬសហការស្រាវជ្រាវអង្កេតជាមួយសមត្ថកិច្ច ហើយធ្វើសំណើរឯកសារ ផ្សព្វផ្សាយជូនសាធារណជន ជូននាយករដ្ឋមន្ត្រី ជូនតុលាការ ជូនសមត្ថកិច្ចនោះវិញ ។

-ចុះត្រួតពិនិត្យតាមមូលដ្ឋាននានា ដើម្បីធ្វើការវាយតម្លៃ និងផ្តល់ឱវាទអំពីសិទ្ធិមនុស្ស ។

-អប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្សជាសាធារណៈ និងតាមមុខសញ្ញានីមួយៗ ។

-ពង្រឹងគណៈកម្មាធិការសិទ្ធិមនុស្ស ឬផ្នែកការងារសិទ្ធិមនុស្ស ឬតំណាងរបស់ខ្លួន នៅតាមគ្រប់ស្ថាប័នរដ្ឋ ឯកជន ខេត្ត ក្រុង ខណ្ឌ ស្រុក និងរៀបចំអោយមានមន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្តនៅតាមសង្កាត់ ឃុំ ភូមិ ។

-ផ្តល់យោបល់ និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីសភាពការណ៍សិទ្ធិមនុស្ស សំដៅធ្វើការកែលំអ និងធ្វើយ៉ាងណាអោយកាន់តែសមស្របនឹងរដ្ឋធម្មនុញ្ញ ច្បាប់ប្រទេស និងអនុសញ្ញាទាំងឡាយរបស់អន្តរជាតិ ។

-លើកមតិ និងចូលរួមគំនិតក្នុងការកែទម្រង់ទាំងឡាយរបស់រាជរដ្ឋាភិបាល ។

-ចូលរួមការប្រជុំគណៈរដ្ឋមន្ត្រី និងការព្រាងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ..... សំដៅផ្តល់យោបល់ពាក់ព័ន្ធនឹងវិជ្ជភាពសិទ្ធិមនុស្ស ។

-សហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីសិទ្ធិកុមារ និងក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដែលជាស្ថាប័នទទួលខុសត្រូវអំពីសិទ្ធិកុមារ និង សិទ្ធិនារី ។

Downloaded from http://www.khmerlaws.com

-ជួយរាជរដ្ឋាភិបាល ជំរុញការងារនីតិរដ្ឋ និង ការបណ្តុះបណ្តាលអ្នកច្បាប់ ។

-ក្នុងនាមរាជរដ្ឋាភិបាល ផ្តល់សេវាប្រឹក្សាច្បាប់ និងការពារក្តីចំពោះជនក្រីក្រ ឬ អ្នកដែលត្រូវអយុត្តិធម៌ទាំងឡាយណាដែលគ្មានលទ្ធភាពទទួលការការពារក្តី ។

-ជាស្ពាន តភ្ជាប់ការងារជាមួយអង្គការសង្គមស៊ីវិល ដើម្បីរួមគ្នាការពារ និងអភិវឌ្ឍន៍វិស័យសិទ្ធិមនុស្សនៅកម្ពុជា ។

មាត្រា ៤ .- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាប្រជុំពេញ ៦ ខែម្តង តាមការអញ្ជើញរបស់ប្រធាន ដើម្បីត្រួតពិនិត្យ វាយតម្លៃការងារ និង លើកទិសដៅការងារ ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជារៀបចំសន្និបាតទូទាំងប្រទេស ២ ឆ្នាំ ម្តង ដើម្បីវាយតម្លៃស្ថានភាពសិទ្ធិមនុស្ស និងលើកសំណើអភិវឌ្ឍន៍ជាបន្តទៀត ។ របាយការណ៍របស់សន្និបាតត្រូវផ្សព្វផ្សាយជាសាធារណៈ ។

មាត្រា ៥ .- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានខុទ្ទកាល័យ និង អនុគណៈកម្មាធិការមួយចំនួន ទទួលការងារជំនាញដូចមាន ៖

- អនុគណៈកម្មាធិការទី ១ ៖ ទទួលការងារបច្ចេកទេសពាក់ព័ន្ធនឹងការស្រាវជ្រាវ ប្រមូលព័ត៌មាន ឯកសារ ធ្វើរបាយការណ៍ពីបទរំលោភសិទ្ធិមនុស្ស ការងារច្បាប់ និងជំនួយការច្បាប់កោសល្យវិច្ច័យជំនាញនានា និងទទួលតាមផ្នែកនីមួយៗ នៃអនុសញ្ញាអន្តរជាតិ ។
- អនុគណៈកម្មាធិការទី ២ ៖ ទទួលការងារបណ្តុះបណ្តាលអប់រំ ផ្សព្វផ្សាយសិទ្ធិមនុស្ស រៀបចំវេទិកាសាធារណៈមតិ លើកលទ្ធភាពអោយមានការស្តាប់ពេញលេញដោយសេរី ។
- អនុគណៈកម្មាធិការទី ៣ ៖ ទទួលទំនាក់ទំនងសាធារណៈ ពាក្យបណ្តឹងតវ៉ា រៀបចំបណ្តាញ និង បណ្តុះបណ្តាលមន្ត្រីឃ្លាំមើលសិទ្ធិមនុស្ស ពិសេសលើកទឹកចិត្តដោះស្រាយទំនាស់ តាមរបៀបសម្រុះសម្រួល ។
- ខុទ្ទកាល័យ ៖ ទទួលការងាររដ្ឋបាល ហិរញ្ញវត្ថុ គ្រប់គ្រង និងសេវានានា បំរើអោយគណៈកម្មាធិការ ។

មន្ត្រីទទួលការងារខុទ្ទកាល័យ អនុគណៈកម្មាធិការ មន្ត្រីជំនាញ ទីប្រឹក្សា ជំនាញការមានឋានៈស្មើ អគ្គនាយក អគ្គនាយករង ប្រធាន អនុប្រធាននាយកដ្ឋាន ។

មាត្រា ៦ .- មន្ត្រី បុគ្គលិក បំពេញការងារក្នុងស្ថាប័ននេះ ជាមន្ត្រីបុគ្គលិករាជការដែលមានក្របខ័ណ្ឌស្រាប់ ឬ ក្របខ័ណ្ឌដែលស្ថាប័នមុខងារសាធារណៈជាអ្នកផ្តល់មកអោយ ។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាអាចទទួលបាននូវអ្នកស្ម័គ្រចិត្តមួយចំនួន ដែលពុំយកប្រាក់បៀវត្សរ៍ពីរដ្ឋ អោយធ្វើជាទីប្រឹក្សា និង អ្នកជំនាញ ។

មាត្រា ៧ .- គណៈកម្មាធិការសិទ្ធិមនុស្ស ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើនឹង អភិបាលរងខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឬជាអភិបាលរងខេត្ត ក្រុង ស្រុក ខ័ណ្ឌ ណាម្នាក់ និងមាន អនុប្រធាន

Downloaded from http://www.khmerlaws.com

ព្រមទាំងសមាជិក មានឋានៈស្មើ អគ្គនាយក អគ្គនាយករងមន្ត្រីអនុវត្ត ក្រុម ប្រធាន អនុប្រធាន ការិយាល័យ ក្រុង ខណ្ឌ ។

**មាត្រា ៨ .-** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ធ្វើការតំណាងអោយរាជរដ្ឋាភិបាលកម្ពុជាក្នុងវិស័យការពារសិទ្ធិមនុស្សកម្ពុជា ។ ប្រធានស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ ជាអ្នកទទួលកិច្ចការនេះប្រចាំនៅអង្គការសហប្រជាជាតិ ដើម្បីឆ្លើយតបទៅតាមការចាំបាច់ រាជរដ្ឋាភិបាលអាចស្នើសុំអោយមានអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាមួយរូបទៀត ប្រចាំនៅអង្គការសហប្រជាជាតិដើម្បីទទួលបន្ទុកសិទ្ធិមនុស្សកម្ពុជា ។

**មាត្រា ៩ .-** រាជរដ្ឋាភិបាលអោយការគាំទ្រផ្នែកធនធានការងារ ថវិកាសំរាប់អោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អាចបំពេញការងាររបស់ខ្លួនបានល្អ ។

**មាត្រា ១០ .-** គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា មានត្រាផ្ទាល់របស់ខ្លួន ។ តួនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ត្រូវកំណត់ជាក់លាក់ដោយអនុក្រឹត្យ ។

**មាត្រា ១១ .-** រាល់បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១២ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៣ .-** ព្រះរាជក្រឹត្យនេះ ត្រូវជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/០១០០/០០៩**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

Downloaded from http://www.khmerlaws.com